## ព្រះរាជក្រឹត្យ នស.រកត.០២០១.០៣៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

លោក គុក វិញ

ជា

ឧកញ៉ា

ភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០១

ព្រះហស្តលេខា

នរោត្តម សីហនុ

## II- រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

### អនុក្រឹត្យ លេខ ១២ អនក្រ.បក

### ស្តីពី ការលុបចោលប្រកាសលេខ ០៧៩ ប្រ.ក.ស.ប.ក. លេខ ៧៨១ ប្រ.ក.ស.ក. និងប្រកាស លេខ ៣២៩ ប្រ.ក.ស.ក. របស់ក្រសួងសាធារណការ និង ដឹកជញ្ជូន

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យ លេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន

-បានឃើញអនុក្រឹត្យ លេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង សាធារណការ និងដឹកជញ្ជូន

-បានឃើញភាពមិនប្រក្រតី នៃប្រកាសចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន

**សម្រេច**

**មាត្រា ១ .-** ចាត់ទុកជានិរាករណ៍នូវ ប្រកាសដែលចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន ដូចខាងក្រោម :

១-ប្រកាសលេខ ០៧៩ ប្រ.ក.ស.ប.ក ចុះថ្ងៃទី១៨ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីការតែងតាំង លោក **ហាន់ សារើ** ជាអនុប្រធានកំពង់ចំលងអ្នកលឿង នៃនាយកដ្ឋានផ្លូវថ្នល់ អគ្គនាយកដ្ឋានសាធារណការ ក្រសួងសាធារណការ និងដឹកជញ្ជូន ។

២-ប្រកាសលេខ ៧៩១ ប្រ.ក.ស.ប.ក ចុះថ្ងៃទី១៦ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការតែងតាំង លោក **ឌុំ អេរ** ជានាយករង នាយកដ្ឋានបុគ្គលិក-ធនធានមនុស្សនៃក្រសួងសាធារណការ និងដឹកជញ្ជូន ។

៣-ប្រកាសលេខ ៣២៩ ប្រ.ក.ស.ក ចុះថ្ងៃទី២១ ខែ កក្កដា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ខុទ្ទកាល័យ ក្រសួងសាធារណការ និងដឹកជញ្ជូន ។ ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវរៀបចំប្រកាសនេះជាថ្មីឡើងវិញ ឱ្យបានសមស្របតាមអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ត្រង់ចំណុចអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី២០-៤-១៩៩៦ ដែលថា : " ភារកិច្ចផ្តល់យោបល់ (របស់ខុទ្ទកាល័យរដ្ឋមន្ត្រី) នេះ មិនផ្តល់សិទ្ធិឱ្យ

ខុទ្ទកាល័យបំពេញការងារជំនួសអង្គភាពមានសមត្ថកិច្ចនៅក្នុងក្រសួង ឬរដ្ឋលេខាធិការដ្ឋាន ឡើយ"

មាត្រា ២ .- រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងសាមីខ្លួន ត្រូវអនុវត្ត អនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

* * *

## អនុក្រឹត្យ លេខ ១៣ អនក្រ.បក

## ស្តីពី ការបង្កើត

## ស្ថានឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជា

## ប្រចាំសាធារណរដ្ឋគុយ៉េ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-យោងតាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ